ខ្ញុំបាទលើកយកឯកសារចាស់មកលាតត្រដាងឡើងវិញនេះ មិនមែនក្នុងផលប្រ-យោជន៍ ដើម្បីទម្លាក់ទោស ឬរិះគន់ចំពោះរឿងរ៉ាវដែលកន្លងផុតទេ ប៉ុន្តែបើគេនិ-យាយអំពីការសម្លាប់រង្គាលរបស់ប៉ុល-ពត និងអំពីគុណបំណាច់ដែលយួនមករំ-ដោះខ្មែរនៅឆ្នាំ១៩៧៩ សូមមេត្តាក្រឡេកមើល ដែលចិនប៉េកាំងនិងយួនហាណូយ បានរៀបចំទុកតាំងពីខែមិនា១៩៧០ផង ។

ដល់មកថ្ងៃទី៣០មេសា១៩៧០, កងទ័ពយួនខាងត្បូងនិងអាមេរិកាំង ចាប់ផ្តើមធ្វើអន្តរាគមន៍ប្រឆាំង«ទីជំរក»វៀកកុងនិងយួនខាងជើង នៅភូមិភាគបូព៌ានៃកម្ពុ-ជា ។ ក្នុងអំឡុងនៃសង្គ្រាមយួន, កងពលធំឧទ្ធម្ភាគចក្រលេខ១អាមេរិកាំង គ្មានសិទ្ធិដើម្បីវាយប្រហារ «ទីជំរក» វៀកកុងនិងយួនខាងជើង នៅក្នុងទឹកដីលាវនិងកម្ពុជាទេ ។ បំរាមនេះបានធ្វើឲ្យក្តៅក្រហាយដល់ពលទាហាននិងមេបញ្ជាការនៃកងពលធំឧទ្ធម្ភាគចក្រ ដែលរងការវាយប្រហារឥតឈប់ឈរ ពីកងកម្លាំងវៀកកុងនិងយួនខាងជើង ដែលលាក់ខ្លួនក្នុងទីជំរកទាំងនេះ ។ ថ្ងៃទី១ឧសភា១៩៧០, ជាទីបញ្ចប់នៃការហាមឃាត់ ។ កងពលធំឧទ្ធម្ភាគចក្រអាមេរិកាំង ចាប់ផ្តើមធ្វើប្រតិបត្តិការរួមគ្នា ជាមួយកងពលធំថ្មើរជើងយួនខាងត្បូង ដោយវាយសំរុកមកក្នុងទឹកដីខ្មែរ ។ យុទ្ធនាការនេះដែលមានរយៈពេល២ខែ បានរុករានទៅដល់ទីជំរកយួនខាងជើងនិងវៀកកុង ។ គោលដៅសំខាន់គឺជំរំនិងមូលដ្ឋានលួចលាក់ សំរាប់គ្រឿងអាវុធនិងស្បៀងអាហារ ដែលបានគំរាមដល់កងទ័ពអាមេរិកាំង និងសម្ព័ន្ធមិត្តយួនខាងត្បូង តាំងពីដើមដំបូងនៃជំនាន់ឆ្នាំ៦០ ។ ការវាយប្រហារនេះ ជាជោគជ័យមិនធ្លាប់មាន ។ ការរកឃើញធំបំផុតក្នុងយុទ្ធនាការ គឺតំបន់ដែលអាមេរិកាំងឲ្យឈ្មោះថា «ប៊ុរី» ។ ក្រុមស៊ើបការណ៍ប្រចាំកងពលធំឧទ្ធម្ភាគចក្រ បានរកឃើញជំរំសំរាប់ហ្វឹកហ្វឺន និងជំរំសំរាប់តម្កល់គ្រឿងអាវុធ ព្រមទាំងស្បៀងអាហារយ៉ាងសំខាន់ ដែលលាតសន្ធឹងលើផ្ទៃដី៣គ.ម.ក្រឡា ។ ក្រោយមកគេបានរកឃើញថែមទៀត នូវឃ្លាំងចំនួនជាង១៨០ អាគារ១៨ខ្នង ដែលជារោងប្រជុំ, កន្លែងរៀនសូត្រ, កន្លែងហ្វឹកហាត់ ហើយនិងព្រមទាំងកន្លែងសំរាប់ចិញ្ចឹមសត្វផង ។ កងទ័ពវៀកកុងនិងយួនខាងជើងបានជន្លៀសខ្លួនចេញអស់ពីតំបន់នេះ ប៉ុន្តែបញ្ជីសំរាប់ផ្គត់ផ្គង់ភស្តុភារនិងពត៌មានផ្សេងទៀត អាចឲ្យដឹងបានថា តំបន់ត្រូវបានប្រើជាឃ្លាំងសំរាប់តំកល់ និងជាមូលដ្ឋានសំរាប់ហ្វឹកហ្វឺនដល់ពលទាហាន ដែលត្រូវបានបញ្ជូនពីយួនខាងជើង។ សម្ភារៈសឹកដែលត្រូវប្រមូលបានពីកន្លែងលាក់នេះមាន ៖ កាំភ្លើងដៃនិងកាំភ្លើងបាញ់យន្តហោះជាង១,៥០០ដើម, មីនប្រឆាំងមនុស្ស២២ហិប, គ្រាប់កាំភ្លើងត្បាល់និងគ្រាប់បែកដៃរាប់ពាន់គ្រាប់ និងអង្ករ៣០តោន ។ ការវាយសំរុកចូលទៅកម្ពុជា បានលទ្ធផលហួសពីការសង្ឃឹមទុក ហើយជាជោគជ័យធំបំផុតពុំធ្លាប់មានរបស់កងព-

លធំឧទ្ធម្ភាគចក្រ ដែលធ្លាប់តែប្រតិបត្តិការតែនៅក្នុងដែនដីយួនខាងត្បូង ដែលជាការបំផុសឲ្យឃើញ នូវការលួកដៃរបស់រាជរដ្ឋាភិបាលខ្មែរក្នុងសង្គ្រាមនៅយួនខាងត្បូង ហើយនៅពេលប្រជារាស្ត្រខ្មែរស្លូតត្រង់ជួបប្រទះលើវិនាសកម្ម ក៏គេពុំដឹងថាមកពីហេតុអ្វី ។ ពួកនាយទាហានអាមេរិកាំងបញ្ជាក់ថា ប្រតិបត្តិការទាំងនេះបានប្រព្រឹត្តទៅដោយយឺតពេល បើគេអាចរារាំងការប្រមូលម្តុំកម្លាំងទ័ពរបស់យៀកកុងនៅខាងក្រៅយួនខាងត្បូងបាន ច្រកចេញនៃសង្គ្រាមត្រូវមានលក្ខណៈប្រែប្រួលទៅផ្សេង ។

នៅប៉េកាំង, ក្នុងថ្ងៃទី៥ឧសភា១៩៧០, ចិនផ្តាច់ចំណងទូតពីភ្នំពេញ និងបានបង្កើត«រណសិរ្សរួបរួមជាតិកម្ពុជា» ។ រាជរដ្ឋាភិបាលនៃរណសិរ្សរួបរួមជាតិកម្ពុជាញ៉ា ត្រូវបានប្រកាសឡើងដែរ ។ បន្ទាប់មក សមាសភាពនៃគណរដ្ឋមន្ត្រីត្រូវបានប្រកាសជាផ្លូវការនៅប៉េកាំង ក្នុងថ្ងៃទី១៣ឧសភា១៩៧០ ។ នាយករដ្ឋមន្ត្រីជាវរជនជើងចាស់ដែលគាំទ្រសីហនុ, ប៉ែន-នុត, ឧបនាយករដ្ឋមន្ត្រី ជាសមាជិករបស់បក្សកុម្មុយនិស្តកម្ពុជា និងជាអតីតតំណាងរាស្ត្រក្នុងរាជរដ្ឋាភិបាល, ខៀវ-សំផន ។ គណៈរដ្ឋមន្ត្រីខ្មែរនៅប៉េកាំង ត្រូវបានផ្សំឡើងពីសមាសធាតុ ជាពួកសីហនុនិយម ។ ប៉ុន្តែ, ដល់ខែវិច្ឆិកា១៩៧៣, គ្រប់ក្រសួងរដ្ឋក្នុងរដ្ឋាភិបាលនៃរណសិរ្សរួបរួមជាតិកម្ពុជា ត្រូវបានផ្ទេរមកនៅក្រោមការកាន់កាប់របស់មេដឹកនាំឧទ្ទាមនៅកម្ពុជាវិញ ។

ចំណែកខាងភ្នំពេញ ការប្រឈមមុខផ្នែកនយោបាយ ដើម្បីទប់ទល់អំពើឈ្លានពានរបស់យួនកុម្មុយនិស្ត បានត្រូវឲ្យមានសន្និសិទមួយស្តីពីបញ្ហាខ្មែរ នៅហ្សាការតាក្នុងថ្ងៃទី១៦-១៧ឧសភា១៩៧០ ។ សេចក្តីថ្លែងការណ៍រួមនៃប្រទេសទាំង១២បានតម្រូវឲ្យពលទាហានបរទេសទាំងអស់ដកថយពីកម្ពុជា, ប៉ុន្តែឥតអំពើ ។

នៅខែវិច្ឆិកា១៩៧០, បន្ទាប់ពីកិច្ចចរចា រវាងតំណាងយួនខាងជើងនិងតំណាងនៃបក្សកុម្មុយនិស្តកម្ពុជា ក្រុមទាំង១០នៃកម្មាភិបាលរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា គឺខ្មែរយៀកមិញប្រមាណ១,០០០នាក់ ដែលបានស្នាក់នៅហាណូយ តាំងពីឆ្នាំ១៩៥៤-១៩៥៥ ចាប់ផ្តើមត្រឡប់មកកម្ពុជាវិញ ។

នៅកម្ពុជា, យៀកកុងនិងយួនខាងជើង កាន់តែមានអនុភាពខ្លាំងឡើង ដោយការគាំទ្រពីប៉េកាំង ហើយជាពិសេសពីរាជរដ្ឋាភិបាលនៃរណសិរ្សរួបរួមជាតិកម្ពុជាដែលមានសីហនុជាមគ្គុទ្ទេសក៏ដ៏ឆ្នើម ។ អំណើះតទៅ, សីហនុបោះបង់ទ្រឹស្តីមួយដែលថាក្រុមបក្សព័ន្ធរបស់គាត់ ឬរាស្ត្រខ្មែរទាំងមូលតស៊ូតែឯកឯង ប្រឆាំង«ចក្រពត្តិនិយមអាមេរិកាំងនិងពួកបរិវារ» ។

នៅថ្ងៃទី២៥មិថុនា១៩៧១, សីហនុបានសារភាពនៅចំពោះមុខនៃអ្នកតំណាងរបស់ទូរទស្សន៍កាណាដា អំពីវត្តមាននៅកម្ពុជា នៃ«គ្រួបង្កាត់យួនខាងជើងប្រមា-

ណា២,០០០នាក់ ដែលជួយជ្រោមជ្រែងដល់ក្រុមបក្សព័ន្ធរបស់គាត់» ។ ចំនួនពិតនៃកងទ័ពកុម្មុយនិស្តនៅកម្ពុជាក្នុងឆ្នាំ១៩៧១ ត្រូវបានផ្សំឡើងដោយពលទាហានយៀកកុងនិងយួនខាងជើង ចំនួន៩០% ។ ចំនួន១០%សេសសល់ជាខ្មែរក្រហមដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកខ្មែរកុម្មុយនិស្ត សាឡុត-សរ, ចំណែកអាតីតខ្មែរយៀកមិញប្រមាណ១,០០០នាក់ ដែលចេញដំណើរពីហាណូយតាមផ្លូវលំហូ-ជីមិញ, បានមកដល់ជាលើកទី១ក្នុងខេត្តក្រចេះ នៅខែកុម្ភៈ១៩៧១ ។ ក្រុមនេះត្រូវបានចាត់តាំងតាមមុខនាទីតូចតាច ដែលគ្មានភាពជាក់លាក់ នៅពាសពេញកម្ពុជា ដោយក្រុមរបស់សាឡុត-សរ ។

នៅថ្ងៃទី២០កញ្ញា១៩៧១, អៀង-សារីបានទៅដល់ក្រុងប៉េកាំង ក្នុងឋានៈជា«បេសកជនពិសេសនៃកងទ័ពរំដោះរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា» ។ ប៉ុន្តែការពិត, មុខនាទីរបស់គាត់គឺឃ្លាំមើលសកម្មភាពរបស់សីហនុ និងពង្រឹងទំនាក់ទំនងរវាងចិនជាមួយបក្សកុម្មុយនិស្តកម្ពុជា ។

ដល់ទៅចុងឆ្នាំ១៩៧១, ក្រុមសេអ៊ីអាអាមេរិកាំងប៉ាន់ប្រមាណថា កងទ័ពខ្មែរក្រហមកំពុងរីកធំធាត់, ផ្នែកយោធានិងនយោបាយ, ក្នុងចំណោមកងទ័ពយៀកកុង ។ ប្រព័ន្ធអំណាចរបស់រណសិរ្សរួបរួមជាតិនៅតំបន់រំដោះប្រែប្រួល ហើយពួកខ្មែរកុម្មុយនិស្តដែលប្រកាន់មាគ៌ាតឹងរ៉ឹងឥតព្រំដែន ចាប់ផ្តើម«ក្តោបក្តាប់» ។ ពាក្យថា«រំដោះ» និង «ស្តេច» ដែលទាំងពីនេះត្រូវបានផ្សំជាមួយសីហនុ, ពេលនោះត្រូវបានប្រើប្រាស់តិចជាងពេលមុន ។ បក្សកុម្មុយនិស្តកម្ពុជាចាប់ផ្តើមស្នើឲ្យយួនបញ្ឈប់សកម្មភាពផ្នែកនយោបាយក្នុងតំបន់រំដោះ ជាទីដែលកងកម្លាំងយៀកកុង នៅតែមានចំនួនច្រើនជាងខ្មែរក្រហម ។

នៅរដូវក្តៅនៃឆ្នាំ១៩៧២, ដោយមានសម្ពាធពីហង់រី-គីហ្ស៊ីហ្គ័រ ទៅលើភាគីយួន, ដំណើរបន្តបន្ទាប់នៃទំនាក់ទំនងនិងកិច្ចចរចាររវាងខ្មែរកុម្មុយនិស្តជាមួយយួន ជាពិសេសជាមួយផាម-ហ៊ុង មកពីតំបន់ណាមបូ ដែលនៅក្នុងនោះ យួនទទូចឲ្យខ្មែរក្រហមចរចាជាមួយលន់-នល់និងអាមេរិកាំង ដើម្បីសំរបសំរួលជាមួយកិច្ចចរចាយួន-អាមេរិកាំង ដែលកំពុងប្រព្រឹត្តនៅទីក្រុងប៉ារីស ។ តាមពិត, ការទទូចបង្ខំរបស់យួនកុម្មុយនិស្តទៅលើខ្មែរក្រហម គឺធ្វើយ៉ាងណាដើម្បីជំរុញសហរដ្ឋអាមេរិកឲ្យឆាប់ដកកងទ័ពពីយួនខាងត្បូង ។ ពីថ្ងៃទី២៤ទៅ២៦មករា១៩៧៣ មានការជួបគ្នាម្តងទៀត រវាងសាឡុត-សរនិងផាម-ហ៊ុង ដែលបានបង្ហាញទៅសាឡុត-សរនូវអត្ថបទថតចម្លងស្តីពីគំរោងនៃកិច្ចព្រមព្រៀង ដែលនឹងត្រូវសំរេចយកដោយការចុះហត្ថលេខានៅក្រុងប៉ារីស ក្នុងថ្ងៃទី២៧មករា១៩៧៣ ថា«កងទ័ពបរទេសទាំងអស់»ត្រូវដកថយពីដែនដីខ្មែរនិងលាវ ។

ខ្មែរក្រហមបានបដិសេធ ហើយចោទប្រកាន់ទាំងល្ងិតល្ងង់ថា «យួនក្បត់» ព្រោះមិនយល់ដល់គំរោងរបស់យួនកុម្មុយនិស្តដែលគិតថា ៖ «បញ្ហាសំខាន់គឺយួនត្រូវធ្វើយ៉ាងណា ដើម្បីឲ្យសហរដ្ឋអាមេរិកឆាប់ដកថយពីឥណ្ឌូចិនសិន មិនខុសគ្នាពីគំរោងដែលចិននិងសូវៀតបានរៀបចំនៅឆ្នាំ១៩៥៤ឯក្រុងហ្សឺណែវ ដើម្បីដេញអាណានិគមបារាំងទេ» ។ ខ្មែរក្រហមចាប់ផ្តើមធ្វើ «បាតុកម្មប្រជាជន» ដែលត្រូវបានរៀបចំឡើងដោយបក្សកុម្មុយនិស្ត នៅតាមតំបន់ដែលកាន់កាប់ដោយខ្មែរក្រហម ដើម្បីស្នើឲ្យយោធភូមិយួនចាកចេញពីកម្ពុជា ។ បាតុកម្មទាំងឡាយនេះ ជាដំណើរចាប់ផ្តើមនៃការពើបប្រយុទ្ធញឹកញាប់ រវាងខ្មែរក្រហមនិងយៀកកុង ដូចជាការប្រយុទ្ធទាំងឡាយដែលកើតមាននៅតំបន់ជុំវិញសៀមរាបជាដើម ។

នៅដំណាច់ខែកុម្ភៈ១៩៧៣, ដោយកាត់តាមផ្លូវលំហូ-ជីមិញ, សីហនុមកទស្សនា«តំបន់រំដោះ» ។ គាត់បានធ្វើដំណើរទៅតំបន់អង្គរក្នុងខេត្តសៀមរាប ហើយបានជួបថ្នាក់ដឹកនាំខ្មែរក្រហម ប៉ុន្តែគ្មានការជួបប្រាស្រ័យជាមួយប្រជាជនសោះឡើយ ។ ទន្ទឹមពេលគ្នា កងកម្លាំងយៀកកុងនិងយួនខាងជើង ដោយសំរបតាមកិច្ចព្រមព្រៀងនៅក្រុងប៉ារីស ចាប់ផ្តើមជន្លៀសខ្លួនពីកម្ពុជា ហើយវិលត្រឡប់ទៅរកទីតាំងនៅតាមបណ្តោយព្រំដែនខ្មែរវិញ ជាពិសេសនៅភូមិភាគឦសាន ដែលយួនយៀកមិញចាប់ផ្តើមតាំងនៅតាំងពីក្រោយសន្និសិទនៅក្រុងហ្សឺណែវក្នុងឆ្នាំ១៩៥៤ រហូតមកទល់រយៈកាលនៃសង្គ្រាមជាមួយអាមេរិកាំង ហើយដែលនឹងក្លាយទៅជាបុព្វ-ហេតុនៃជម្លោះជាមួយរបបប៉ុល-ពត ក្រោយថ្ងៃទី១៧មេសា១៩៧៥ ។ ឧប្បត្តិហេតុជាមួយខ្មែរក្រហមកាន់តែកើតឡើងញឹកញាប់ ក្នុងពេលដកថយ ។

ក្នុងខណៈនោះ, បន្ទាប់ពីការផ្អាកនូវការទម្លាក់គ្រាប់បែកលើយួនខាងត្បូងនិងលាវ តាមកិច្ចព្រមព្រៀងនៅក្រុងប៉ារីស កងអាកាសចរណ៍អាមេរិកាំងបានបង្កើនការទម្លាក់គ្រាប់បែកនៅកម្ពុជា ដោយសារការរឹងរូសរបស់ខ្មែរក្រហម ដែលមិនព្រមធ្វើកិច្ចចរចា និងដើម្បីគាំទ្រដល់កងទ័ពនៃសាធារណរដ្ឋខ្មែរ ។ នៅថ្ងៃទី២០មិនា១៩៧៣, សមូហភាវូបនីយកម្មផ្នែកកសិកម្មនៅកម្ពុជា បានចាប់ផ្តើមឡើងតាមតំបន់របស់ខ្មែរក្រហម ។ តំណែទម្រង់ខាងវិស័យកសិកម្ម បានជំរុញរាស្ត្រខ្មែរ៣០,០០០នាក់ ឲ្យរត់ទៅជ្រកនៅយួនខាងត្បូង, ហើយ២០,០០០នាក់ទៀត មករស់នៅក្រោមការគ្រប់គ្រងនៃរបបសាធារណរដ្ឋ ។ នៅ«តំបន់រំដោះ» មានការសរិតសំរាំងលើពួកសីហនុនិយម ទៅក្នុងចលនាប្រឆាំងជាមួយលន់-នល់ និងការបំបាត់គណាមន្ត្រីសង្ឃ ។ ខ្មែរក្រហមសំដែងហឹង្សាចំពោះសីហនុ យួន និង«ខ្មែរហាណូយ» ដែលបានត្រឡប់មកកម្ពុជាវិញ នៅឆ្នាំ១៩៧០-១៩៧២ ។ ពួកខ្មែរយៀកមិញជើងចាស់ទាំងនេះ ត្រូវបានសរឹតសំរាំងដោយស្ងៀមស្ងាត់, ប៉ុន្តែតាមប្រព័ន្ធច្បាស់លាស់, ចេញ

ពីបក្សកុម្មុយនិស្តកម្ពុជា ។ អ្នកខ្លះបានសំរេចចិត្តដើម្បីគេចខ្លួនពីការសំរិតសំរាំង នេះ ដោយត្រឡប់ទៅប្រទេសយួនវិញជាមួយយៀកកុង ដូចកាលពីឆ្នាំ១៩៥៤-១៩៥៥ ប៉ុន្តែភាគច្រើនត្រូវបានពិឃាត ដោយក្រុមរបស់សាឡុត-សរ ចំណែកខាងយួន ពួកគេកាត់បន្ថយយ៉ាងសន្ធឹកសន្ធាប់ នូវការបញ្ជូនអាវុធចំពោះខ្មែរក្រហម ។

នៅថ្ងៃទី១៥កក្កដា១៩៧៣ សភាអាមេរិកាំងបានបោះឆ្នោត ដើម្បីអនុម័តបញ្ឈប់ការទម្លាក់គ្រាប់បែកលើកម្ពុជា ។ តាំងពីឆ្នាំ១៩៦៩ គ្រាប់បែកប្រមាណជាង៥០ម៉ឺនតោន ត្រូវបានទម្លាក់លើកម្ពុជា ។ ជាងពាក់កណ្តាលនៃគ្រាប់នេះ ២៥៧,៤៦៥តោន ត្រូវបានទម្លាក់ ចាប់ពីត្រឹមតែខែមករា១៩៧៣ មកទល់ខែកក្កដា១៩៧៣នេះ, ដើម្បីការពារក្រុងភ្នំពេញ ពីការវាយប្រហារផ្តាច់ព្រ័ត្ររបស់ក្រុមសាឡុត-សរនៅឆ្នាំ១៩៧៣ ។ ដល់មកថ្ងៃទី២៧សីហា១៩៧៣ ឧត្តមសេនីយ៍ស៊ីសុវត្ថិ-សិរីមតៈ បានផ្ញើរលិខិតចំហមួយទៅជូនសីហនុ ជាបងប្អូនជីដូនមួយ ដោយណែនាំសីហនុឲ្យដឹងខ្លួនចំពោះកំហុសទាំងឡាយ និងឲ្យដកខ្លួនពីពួកកុម្មុយនិស្តអាស៊ី ។

បន្ទាប់ពីការដកថយនៃកងទ័ពយៀកកុងនិងយួនខាងជើង, ខ្មែរក្រហមដែលមានពលទាហានកាន់តែច្រើន បានបើកការវាយលុកយ៉ាងធំទៅលើទីក្រុងកំពង់ចាម នៅថ្ងៃទី១កញ្ញា១៩៧៣ ដែលស្ថិតនៅចម្ងាយ១២០គ.ម.ខាងព្យសាននៃក្រុងភ្នំពេញ នាត្រើយខាងលិចនៃទន្លេមេគង្គ ។ ប៉ុន្តែពួកនេះ ត្រូវបានវាយរុញច្រានថយក្រោយវិញ ដោយទទួលការខូចខាតជាទម្ងន់ បន្ទាប់ពីការប្រយុទ្ធយ៉ាងសាហាវ អស់រយៈពេលពីរសប្តាហ៍ ដែលនៅឱកាសនោះ កងនាវាចរណ៍ខ្មែរបានបំពេញមុខនាទីយ៉ាងសំខាន់ ។

ពីការប្រយុទ្ធនេះ, ខ្មែរក្រហមចង់បង្ហាញជំហរឯករាជ្យម្ចាស់ការរបស់ខ្លួន ។ ប៉ុន្តែតាមពិត ដូចជានៅថ្ងៃទី៤មិនា១៩៧៤, ឡេ-ឌឹកថូ បានទទួលលិខិតមួយពីសាឡុត-សរ ដែលនៅក្នុងនោះ សាឡុត-សរបានអះអាងអំពី«ភក្តីភាពនៃបក្សកុម្មុយនិស្តកម្ពុជា ចំពោះមិត្តភាព ភាតរភាព និងសាមគ្គីភាព រវាងប្រជាជនទាំងពីរ» ។

យ៉ាងណាក៏ដោយ, ការព្រួយបារម្ភរបស់សាឡុត-សរ ចំពោះឧបស័គ្គទៅអនាគត និងចំពោះយួន ដែលតាំងខ្លួនជានិច្ចជាអ្នកត្រួតត្រា ឬជាអ្នកបណ្តុះបណ្តាល បានជំរុញសាឡុត-សរឲ្យព្យាយាមកំចាត់ពួកកម្មាភិបាលខ្មែរដែលត្រឡប់មកពីហាណូយ ត្រូវបានសម្លាប់ចោលស្ទើរតែទាំងអស់ ។

ប៉ុន្តែ, ចំពោះមុខយួន, សាឡុត-សរបន្តសំដែងមិត្តភាពដូចជាតាមលិខិត ដែលគណកម្មាធិការមជ្ឈឹមនៃបក្សពលករយួនបានទទួលពីសាឡុត-សរ នៅថ្ងៃទី៣តុលា១៩៧៤ថា ៖ «បក្សរបស់យើងដើរតាមមាគ៌ានយោបាយត្រឹមត្រូវ, ប៉ុន្តែជ័យជំនះរបស់យើង មិនអាចត្រូវបំបែកចេញ ពីការឧបត្ថម្ភរបស់បក្សពលករវៀតណាម